31/5

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ២០៨ អ.ក

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១

សាលក្រមព្រហ្មទណ្ឌលេខ៖ ៨២ "ន"

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាអសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង០៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted]ៅក្រុមប្រឹក្សា

លោក [redacted] ចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ២០៨ អ.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] អេង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករផ្សារដែក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ឆ្នួញ (រស់) ម្ដាយឈ្មោះ [redacted] សាម៉េត (រស់) ជាអនីតិជន នៅលីវ កំរិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ០២ឆ្នាំ ពីបទ លួច។ **(ឃុំខ្លួនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១)**

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **អេង។**

**ជាប់ចោទពីបទ:** **"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ៧៨២ ដកសព ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

**-បានឃើញ** ដីកាដំណោះស្រាយលេខ: ៨៤៣/២១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

**-បានឃើញ** ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជំរះលេខ: ៧២៧ ដកចត/២១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ របស់ប្រធាន សាលាដំបូងខេត្តកណ្ដាល។



Scanned with CamScanner

## អង្គហេតុមានដូចតទៅ៖

កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១១ និង ៣០នាទី មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កើតឡើងនៅចំណុចភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ឆេង និងឈ្មោះ [redacted] សុខឡាយ ជាមុខសញ្ញាជួញដូរថ្នាំញៀនយ៉ាងសកម្មនៅក្នុងមូលដ្ឋានភូមិស្វាយតានី ឃុំព្រែកគយ។ ដែលថ្នាំញៀន ជនសង្ស័យបានទិញពីបុរសមិនស្គាល់ឈ្មោះ ក្នុងតម្លៃ៤ម៉ឺនរៀល ដើម្បីយកមកវែកជាកញ្ចប់តូចៗ ដើម្បីលក់ទៅឱ្យម៉ូយនៅក្នុងភូមិ តម្លៃ ១៥០០០ រៀល ក្នុង១កញ្ចប់។ ក្រោយពីទទួលពត៌មានពីប្រជាពលរដ្ឋក្នុងភូមិ សមត្ថកិច្ចបានចុះទៅដល់កន្លែងកើតហេតុ ហើយធ្វើការបង្ក្រាប និងឃាត់ខ្លួនជនសង្ស័យចំនួន ២នាក់ ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០៧ កញ្ចប់ (០១ កញ្ចប់ធំ និង ០៦កញ្ចប់តូច) រួមទាំងសម្ភារៈសម្រាប់វេចខ្ចប់ថ្នាំញៀនមួយចំនួន បញ្ជូនមកកាន់អធិការដ្ឋាន់នគរបាលស្រុកស្អាង ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។ ក្រោយបញ្ចប់ការស៊ើបសួរ ឃើញថា ជនត្រូវចោទឈ្មោះ ឆេង សុខឡាយ ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ចៅក្រមស៊ើបសួរបានសម្រេចលើកលែងការចោទប្រកាន់លើឈ្មោះ ឆេង សុខឡាយ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឆេង បានឆ្លើយបដិសេធថា៖ ខ្លួនសុំបដិសេធចម្លើយទាំងស្រុងនៅសមត្ថកិច្ច ដោយសារគេបង្ខំខ្លួនឱ្យឆ្លើយ។ ខ្លួន និងឈ្មោះ [redacted] សុខឡាយ គឺធ្វើការជាអ្នករត់តុជាមួយគ្នានៅហាងឈ្មោះ [redacted] គីមម៉េង ពីម៉ោង ៧យប់ដល់ម៉ោង ១២រំលងអាធ្រាត បន្ទាប់ពីចប់ការងារ ខ្លួនក៏ជិះម៉ូតូមកដល់រង្វង់មូលហាង់ ក៏បានជួបឈ្មោះ វីរៈ ហើយខ្លួនចុះទៅសួរថាមានកន្លែងដេកអត់ ហើយឈ្មោះ វីរៈ ថាមានដោយបានជួលបន្ទប់ផ្ទះសំណាក់រួចហើយ ទើបខ្លួន និងឈ្មោះ [redacted] សុខឡាយ អត់ទៅផ្ទះទេ ក៏ដេកនៅផ្ទះសំណាក់ជាមួយឈ្មោះ វីរៈ ព្រោះផ្ទះខ្លួននៅឆ្ងាយ ផ្លូវស្ងាត់ពិបាកធ្វើដំណើរ ទើបខ្លួន និងឈ្មោះ [redacted] សុខឡាយ ជិះម៉ូតូទៅផ្ទះសំណាក់នោះ ហើយអង្គុយហូបមីមួយសន្ទុះ ស្រាប់តែឈ្មោះ វីរៈ បានពឹងខ្លួនឱ្យទៅឱបនារីម្នាក់មកដេកជាមួយ ហើយខ្លួនបានទៅឱបនារីនោះដល់បន្ទប់ផ្ទះសំណាក់ ហើយនារីនោះទៅជួលបន្ទប់មួយទៀតនៅជិតនោះដែរ។ ពេលនោះប្អូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សុខឡាយ ដេកលក់មុន ហើយខ្លួនក៏ដេកតាមក្រោយ ដោយមិនបានដឹងថាឈ្មោះ វីរៈ ចេញពីបន្ទប់តាំងពីពេលណានោះទេ។ ក្រោយមកខ្លួនដេករហូតដល់ម៉ោង ១០ ព្រឹក ស្រាប់តែម្ចាស់ផ្ទះមកហៅ ថាមានមិត្តភក្តិមករក ពេលខ្លួនភ្ញាក់ឡើងឃើញឈ្មោះ [redacted] សុខឡាយ ដែលនៅដេកក្នុងបន្ទប់នោះ អត់ឃើញឈ្មោះ វីរៈ នោះទេ ចំណែកម៉ូតូ និងកាបូបរបស់ឈ្មោះ វីរៈ ក៏នៅក្នុងបន្ទប់នោះដែរ។ ពេលខ្លួនបើកទ្វារឡើងក៏ឃើញសមត្ថកិច្ចមកសួររកឈ្មោះ វីរៈ ហើយដើររកជុំវិញនោះ និងបានបើកមើលកាបូបរបស់ឈ្មោះ វីរៈ ក៏ឃើញថ្នាំញៀន និងសម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួននៅក្នុងនោះ លុះពេលដែលសមត្ថកិច្ចឃាត់ខ្លួនចេញមកក្រៅ ក៏ឃើញឈ្មោះ វីរៈ នៅទីនោះដែរ ហើយប៉ូលីសបង្ខំឱ្យខ្លួនទទួលស្គាល់ថ្នាំញៀនមួយចំនួននោះថាជារបស់ខ្លួន បើខ្លួនមិនទទួលស្គាល់ទេ ប៉ូលីសនឹងវាយខ្លួន។ ខ្លួនមិនធ្លាប់ជួញដូរថ្នាំញៀនទេ ហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតនោះ ជារបស់ឈ្មោះ វីរៈ វាមិនមែនជារបស់ខ្លួននោះទេ ហើយខ្លួនក៏មិនធ្លាប់ជួញដូរថ្នាំញៀនដែរ។ មុនពេលឃាត់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀនជាមួយអ្នករួមការងារ។

-<u>ក្រឡាបញ្ជីអាន៖</u>ឯកសារនានាក្នុងសំណុំរឿង។

-<u>សិទ្ធិនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល</u>

ការកត់សំគាល់របស់ជនជាប់ចោទ៖ សូមតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់នេះផង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ឆេង ថា ថ្នាំញៀនដែលសមត្ថ



Scanned with CamScanner

កិច្ចដកហូតបានមិនមែនជារបស់ខ្លួននោះទេ ដែលចម្លើយនេះពុំមានភស្តុតាងគ្រប់គ្រាន់អាចឱ្យជឿបានទេ ព្រោះសមត្ថកិច្ចដកហូតវត្ថុតាងថ្នាំញៀនជាក់ស្តែងពីជនជាប់ចោទ ដូចនេះតំណាងអយ្យការ ធ្វើសេចក្តីសន្និដ្ឋានការពារការចោទប្រកាន់ និងសុំរក្សាទុកការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៧៨២ ដកសព ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ទុកជាបានការដដែល។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖** កូនក្តីរបស់ខ្លួនដែលមានឈ្មោះ [redacted] ឆេង មិនបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ ម្យ៉ាងវិញទៀត បញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក៏មិនត្រូវបានអនុវត្តដែរ ដោយហេតុថា ខ្វះធាតុផ្សំនៃបទល្មើស គឺធាតុសត្យានុម័ត ធាតុអត្តនោម័ត និងមិនមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថា កូនក្តីខ្លួនពិតជាបានប្រព្រឹត្តនូវបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះទេ ដែលនេះជាវិមតិសង្ស័យដែលជាប្រយោជន៍ដល់កូនក្តីរបស់ខ្លួនតាមមាត្រា ៣៨ កថាខណ្ឌទី៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឆេង សូមស្នើឱ្យប្រធានក្រុមប្រឹក្សា ចៅក្រមប្រឹក្សា មេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់នេះផង។

## ផ្អែកតាមកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ឆេង។

-ក្រោយពីបានពិនិត្យឯកសារនានាកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យ ពិភាក្សាក្រុមប្រឹក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

## តុលាការយល់ឃើញថា៖

១-កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១១ និង ៣០ នាទី នៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ឆេង** ពិតប្រាកដមែន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឆេង** នាពេលសវនាការបានឆ្លើយបដិសេធថា៖ ខ្លួន និងឈ្មោះ [redacted] សុខឡាយ បានទៅស្នាក់នៅផ្ទះសំណាក់ជាមួយឈ្មោះ វីរៈ។ ពេលនោះខ្លួន និងឈ្មោះ [redacted] សុខឡាយ ក៏ដេកនៅក្នុងបន្ទប់ផ្ទះសំណាក់នោះទៅ ដោយមិនបានដឹងថាឈ្មោះ វីរៈ ចេញពីបន្ទប់តាំងពីពេលណានោះទេ។ ក្រោយមកខ្លួនដេករហូតដល់ម៉ោង ១០ ព្រឹក ស្រាប់តែម្ចាស់ផ្ទះមកហៅ ថាមានមិត្តភក្តិមករក ពេលខ្លួនភ្ញាក់ឡើងឃើញឈ្មោះ [redacted] សុខឡាយ ដែលនៅដេកក្នុងបន្ទប់នោះ អត់ឃើញឈ្មោះ វីរៈ នោះទេ ចំណែកម៉ូតូ និងកាបូបរបស់ឈ្មោះ វីរៈ ក៏នៅក្នុងបន្ទប់នោះដែរ។ ពេលខ្លួនបើកទ្វារឡើងក៏ឃើញសមត្ថកិច្ចមកសួររកឈ្មោះ វីរៈ ហើយដើររកជុំវិញនោះ និងបានបើកមើលកាបូបរបស់ឈ្មោះ វីរៈ ក៏ឃើញថ្នាំញៀន និងសម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួននៅក្នុងនោះ លុះពេលដែលសមត្ថកិច្ចឃាត់ខ្លួនចេញមកក្រៅ ក៏ឃើញឈ្មោះ វីរៈ នៅទីនោះដែរ ហើយប៉ូលីសបង្ខំឱ្យខ្លួនទទួលស្គាល់ថ្នាំញៀនមួយចំនួននោះថាជារបស់ខ្លួន បើខ្លួនមិនទទួលស្គាល់ទេ ប៉ូលីសនឹងវាយខ្លួន។ ខ្លួនមិនធ្លាប់ជួញដូរថ្នាំញៀនទេ ហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតនោះ ជារបស់ឈ្មោះ វីរៈ វាមិនមែនជារបស់ខ្លួននោះទេ



Scanned with CamScanner

ហើយខ្លួនក៏មិនធ្លាប់ជួញដូរថ្នាំញៀនដែរ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឆេង គ្រាន់តែឆ្លើយដោះសារដើម្បីបាន រួចខ្លួនពីការចោទប្រកាន់តែប៉ុណ្ណោះ ដោយហេតុថា ជាក់ស្តែងសមត្ថកិច្ចដកហូតថ្នាំញៀនពីឈ្មោះ [redacted] ឆេង ចំណែកឈ្មោះ វី រ: មិនមានក្នុងរបាយការណ៍របស់សមត្ថកិច្ចនោះទេ យោងតាមរបាយការណ៍សរុបការស៊ើបអង្កេតបទល្មើស ជាក់ស្តែងលេខ ០២៥ របក របស់អធិការនគរបាលស្រុកស្អាង និងក្រោយពីបានពិនិត្យ លើភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ឆេង ពិតជាបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។

៣-តាមកំណត់ហេតុបើកធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ឃើញថា វត្ថុតាងជាប្រភេទម្សៅក្រាមពណ៌សថ្លាចំនួន ៧កញ្ចប់ ថ្លឹងដោយជញ្ជីងម៉ាក FEM 202 ទម្ងន់ 0,៧៦ក្រាម ដើម្បីសាកល្បងធ្វើតេស្តលើម្សៅសក្រាមទាំងនោះ ដែលសង្ស័យជាសារធាតុញៀន ជាលទ្ធផលដែលបានមកពីការប្រតិកម្មរបស់ឧបករណ៍ពិសោធន៍ប្រភេទ Marquis Regent បានបង្ហាញវត្ថុមានជាសារធាតុ **មេតំហ្វេតាមីន**។

**៤-**អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ឆេង** មានចេតនាទុច្ចរិតក្នុងការធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដើម្បីបានប្រាក់ចំណេញ ដែលមានទម្ងន់សរុប 0,៧៦ ក្រាម គឺជាបទល្មើសព្រហ្មទណ្ឌ បទ: “**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**” ប្រព្រឹត្តនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

**៥-**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆេង** ពីបទ“**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**” ឃើញថា មានលក្ខណ:ត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាការប្តឹងសុំនេះ។

៦-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ។ ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការសម្រេចតាមការស្នើសុំបានទេ។

៧-ជនជាប់ចោទឈ្មោះ [redacted] ឆេង ជាអនីតិជន មានស្មារតីគ្រប់គ្រាន់អាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៨-ក្រោយពីបានពិនិត្យ និងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ឆេង** ពីបទ “**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**” ប្រព្រឹត្តនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

**៩-**អំពីដែលជនជាប់ចោទឈ្មោះ [redacted] **ឆេង** ប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សុខភាព ប៉ះពាល់ដល់របៀបរៀបរយ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ។

**១០-**ជនជាប់ចោទឈ្មោះ [redacted] **ឆេង** ជាអនីតិជន ដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោស ដោយអនុវត្តតាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ និងចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

**១១-**វត្ថុចាប់យក៖

ក-ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀនប្រភេទម៉ាទីកកចំនួន ០៧កញ្ចប់តូច ទម្ងន់ 0,៧៦ក្រាម វេចខ្ចប់ដាក់ក្នុង



Scanned with CamScanner

ស្រោមសំបុត្រធំ ពណ៌គគីរ បិតជិតគ្មានលេខកូដ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន គប្បីរឹបអូស និងបំផ្លាញចោលតាមមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ទូរស័ព្ទដៃចំនួន ០២គ្រឿង ម៉ាកអាយហ្វូនស៊ិច ពណ៌ខ្មៅ និងម៉ាក Oppo គប្បីសម្រេចរឹបអូសតាម ៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆេង** ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន **២,០០០,០០០ (ពីរលាន) រៀល**។

ជាប់ចោទពីបទ៖**"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"**ប្រព្រឹត្តនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ និងចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ**។

**២-វត្ថុចាប់យក៖**

ក-ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀនប្រភេទម៉ាទឹកកកចំនួន ០៧កញ្ចប់តូច ទម្ងន់ ០,៧៦ក្រាម វេចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ ពណ៌គគីរ បិតជិតគ្មានលេខកូដ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន សម្រេចរឹបអូស និងបំផ្លាញចោលតាមមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ-ទូរស័ព្ទដៃចំនួន ០២គ្រឿង** ម៉ាកអាយហ្វូនស៊ិច ពណ៌ខ្មៅ និងម៉ាក Oppo សម្រេចរឹបអូសតាម ៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និងប្រកាសជាអសារធារណៈនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឆេង**។

-រក្សាសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានឃើញ

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កណ្តាល, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សា**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កណ្តាល, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner